# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៣៚៙៣៚៙៣៚៙

## ញត្តិរបស់ក្រុមសមាគម អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច

## ជូនចំពោះ

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន

យើងខ្ញុំជាសមាគម អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋខ្មែរដែលស្រលាញ់ធនធានធម្មជាតិ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរឹតត្បិត សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន សមាគម អង្គការសង្គមស៊ីវិល និងការរកឃើញជាបន្តបន្ទាប់នូវបទល្មើសធនធានធម្មជាតិ ក៏ដូចជា ការកាប់រានទន្ទ្រានយកដីព្រៃនៅក្នុងតំបន់ការពារធម្មជាតិ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ។ រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ស្ថានភាពគម្របព្រៃឈើនៅក្នុងប្រទេសកម្ពុជា បានបន្តធ្លាក់ចុះយ៉ាងរហ័ស ពីចំនួន ៦១.១៥% នៅឆ្នាំ២០០២ មកត្រឹមតែ ៤៦.៨៦% គិតត្រឹមឆ្នាំ២០១៨។ ប្រទេសកម្ពុជា ធ្លាប់ខកខានមិនបានបំពេញតាមសូចនាករណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលមានគោលដៅរួម លុបបំបាត់នូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការធានានិរន្តរភាពបរិស្ថាន និងការថែរក្សាឱ្យបានគម្របព្រៃឈើ ៦០% នៅឆ្នាំ២០១៥។[1] និន្នាការបន្តការធ្លាប់ចុះនៃគម្របព្រៃឈើនេះ ជាសញ្ញាបង្ហាញពីការព្រួយបារម្ភចំពោះការខកខានម្តងទៀត ពីការមិនអាចអនុវត្តន៍បាននូវទិសដៅក្នុងការបង្កើតគម្របព្រៃឈើឡើងវិញឱ្យបាន ៦០% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជាត្រឹមឆ្នាំ ២០២៩។[2]

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានចេញរបាយការណ៍ថ្មីមួយមានចំណងជើងថា "ការកាប់ឈើខុសច្បាប់ធ្វើឱ្យអន្តរាយដល់សិទ្ធិ និងវប្បធម៌របស់ជនជាតិដើមភាគតិច" ។ របាយការណ៍នេះបានបង្ហាញថា នៅក្នុងឆ្នាំ២០២១ គម្របព្រៃឈើចំនួនប្រមាណ ៦,២៧១ហិកតា ត្រូវបានកាប់បំផ្លាញនៅក្នុងដែនជម្រកសត្វព្រៃចំនួនពីរ គឺដែនជម្រកសត្វព្រៃព្រៃឡង់ និងដែនជម្រកសត្វព្រៃព្រះរកា។[3] ខណៈដែលរបាយការណ៍ស្តីពី ការឃ្លាំមើលព្រៃឈើនៅកម្ពុជាមួយទៀត បានបង្ហាញថា គម្របព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ និងដែនជម្រកសត្វព្រៃព្រះរកា បានបាត់បង់នៅក្នុង

---

[1] រាជរដ្ឋាភិបាល, *គោលនយោបាយកម្មវិធីព្រៃឈើជាតិ*, (២០១០៖ ភ្នំពេញ), ៣។

[2] រាជរដ្ឋាភិបាល, *គោលនយោបាយកម្មវិធីព្រៃឈើជាតិ*, (២០១០៖ ភ្នំពេញ), ៣០។

[3] Amnesty International, *Cambodia: Illegal logging harming Indigenous peoples' rights and cultures – new research* (Published: January 28, 2022), Website: https://bit.ly/3tShanc (Viewed: March 20, 2022).

ឆ្នាំ២០២០ មានចំនួន ១០,០០០ហិកតា។[4] នោះជាទិន្នន័យថ្មីបំផុត ដែលបានរកឃើញបន្ទាប់ពីអង្គការគំនិតផ្ដួចផ្ដើមសកលប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលបានចុះផ្សាយកាលពីឆ្នាំ២០២១ ពីការបាត់បង់គម្របព្រៃឈើក្នុងទំហំ ៥៥៧.០០០ ហិកតា ដែលស្មើនឹងប្រមាណ ១១,៧% នៃតំបន់ការពារធម្មជាតិរបស់កម្ពុជាក្នុងចន្លោះឆ្នាំ ២០០១ និងឆ្នាំ ២០១៨។[5]

ស្របពេលដែលគម្របព្រៃឈើកម្ពុជា នៅតែបន្តរកឃើញពីការបាត់បង់ និងការលួចបំផ្លាញ យើងអង្កេតឃើញថា ការរឹតត្បិតសិទ្ធិសេរីភាព ចំពោះការចូលរួមក្នុងការការពារព្រៃឈើ ធនធានធម្មជាតិដោយស្ម័គ្រចិត្ត ដូចជា សកម្មភាពល្បាតព្រៃរបស់បណ្ដាញសហគមន៍ព្រៃឡង់ បណ្ដាញសហគមន៍ព្រៃព្រះរកា ក្រុមសកម្មជនព្រៃឈើ សមាគម និងអង្គការសង្គមស៊ីវិល។

ដោយមើលឃើញពីលំហាចូលរួមរបស់សហគមន៍មូលដ្ឋាន សកម្មជន សមាគម អង្គការសង្គមស៊ីវិលនៅតែបន្តរងការរឹតត្បិត ស្របពេលដែលគម្របព្រៃឈើនៅតែបន្តរកឃើញថា មានការបាត់បង់ជាបន្តបន្ទាប់គួរឱ្យព្រួយបារម្ភ ។ ដើម្បីថែរក្សា ការពារ និងសហការឱ្យមានតម្លាភាពក្នុងការចូលរួមថែរក្សា ការពារគម្របព្រៃឈើដែលនៅសេសសល់រួមគ្នាឈរលើស្មារតីអ្នកស្រឡាញ់ព្រៃឈើ និងការចូលរួមប្រកបដោយបរិយាប័ន្ន យើងខ្ញុំជាសហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច សមាគម អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរអ្នកស្រលាញ់ធនធានធម្មជាតិ ស្នើទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានដូចខាងក្រោម៖

1. ស្នើឱ្យក្រសួងបរិស្ថានអនុវត្តន៍ការប្ដេជ្ញាចិត្តរបស់ខ្លួន ឱ្យបានខ្ជាប់ខ្ជួន ដូចមានចែងនៅក្នុងកម្មវិធីព្រៃឈើជាតិ សម្រាប់ដាក់ឱ្យអនុវត្តន៍ពីឆ្នាំ២០១០ ដល់ ២០២៩ និងការប្ដេជ្ញាចិត្តរបស់ក្រសួងក្នុងសន្និសីទក្របខ័ណ្ឌអង្គការសហប្រជាជាតិស្ដីពី ការប្រែប្រួលអាកាសធាតុលើកទី២១ (COP21) ២០១៥ នៅទីក្រុងប៉ារីស ដែលសន្យាថែរក្សាគម្របព្រៃឈើឱ្យបាន ៦០ភាគរយ ត្រឹមឆ្នាំ២០៣០។
2. យកចិត្តទុកដាក់ទប់ស្កាត់បទល្មើសធនធានធម្មជាតិ ផ្ដន្ទាទោសដល់អ្នកទិញ-លក់ឈើខុសច្បាប់ព្រមទាំងស៊ើបអង្កេតរកអ្នកពាក់ព័ន្ធ និងអនុវត្តន៍ច្បាប់ឱ្យខានតែបានចំពោះការប្រព្រឹត្តអំពើពុករលួយគ្រប់ប្រភេទ ដែលបណ្ដាលឱ្យបាត់បង់ធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា ។
3. ត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យា និងអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច ក្នុងនោះត្រូវបើកទូលាយឱ្យអ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ សមាគម អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងសាធារណជនចូលរួមតាមដាន និងអង្កេត ដើម្បីធានានូវតម្លាភាព ។
4. បើកទូលាយក្នុងការអនុវត្តសិទ្ធិ និងករណីកិច្ចនានាចំពោះសហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច សាធារណជន សមាគម អង្គការសង្គមស៊ីវិល ស្របតាមច្បាប់ស្ដីពីតំបន់

[4] VOD, Prey Lang, *Prey Preah Roka Monitors Suppressed While Tree Cover Vanishes: Report*, (Published: Thu Jan 27, 2022 11:33 am), Website: https://bit.ly/3qCmD0x (Viewed: March 20, 2022).
[5] គេហទំព័រសំឡេងសហរដ្ឋអាមេរិកផ្សាយជាខេមរភាសា, *អង្គការ Amnesty International៖ ព្រៃឡង់ស្ថិតក្នុងហានិភ័យធ្ងន់ធ្ងរ ខណៈមិនមានវត្តមានអ្នកល្បាតព្រៃសហគមន៍*, ២៥ កុម្ភៈ ២០២១ ,Website: https://bit.ly/3D8Ly0Z។(ទស្សនា ៣០ មិថុនា ២០២១)

ការពារធម្មជាតិ ក្នុងមាត្រា២១ មាត្រា២២ មាត្រា២៩ និងមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនង និងព័ត៌មាន៖**


**លោក ហេង គីមហុង** ប្រធានផ្នែកកម្មវិធីស្រាវជ្រាវ និងតស៊ូមតិនៃសមាគមបណ្តាញយុវជនកម្ពុជា
0967 888 368

**លោក ហឿន សុភាព** អ្នកសម្របសម្រួលបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ
0966 328 573


**ញត្តិនេះគាំទ្រដោយ៖**

| | | |
|---|---|---|
| 1) | សមាគមបណ្តាញយុវជនកម្ពុជា | CYN |
| 2) | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | CCHR |
| 3) | បណ្តាញសហគមន៍ព្រៃឡង់ | PLCN |
| 4) | អង្គការស្ពានសន្តិភាព | PBO |
| 5) | អង្គការពន្លកខ្មែរ | PKH |
| 6) | អង្គការជនជាតិដើមភាគតិចកម្ពុជា | CIPO |
| 7) | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន | YRDP |
| 8) | អង្គការសម្ព័ន្ធការពារសិទ្ធិមនុស្សកម្ពុជា | CHRACK |
| 9) | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព | PDP-Center |
| 10) | សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម | CISA |
| 11) | សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ | KSILA |
| 12) | បណ្តាញព្រៃព្រះរកា | ខេត្តព្រះវិហារ |
| 13) | សហគមន៍ជនជាតិដើមភាគតិចកួយភូមិប្រមេរ | ខេត្តព្រះវិហារ |
| 14) | អង្គការអនុផលព្រៃឈើ | ខេត្តព្រះវិហារ |
| 15) | សហគមន៍ព្រៃឈើសាមគ្គី | ខេត្តស្ទឹងត្រែង |
| 16) | សហគមន៍ព្រៃឈើវាលកន្សែង | ខេត្តក្រចេះ |
| 17) | សហគមន៍ព្រៃឈើក្បាលខ្លា | ខេត្តកំពង់ធំ |
| 18) | សហគមន៍នេសាទបឹងធំ | ខេត្តកំពង់ធំ |
| 19) | សហគមន៍ព្រៃឈើភ្នំបាក់ | ខេត្តក្រចេះ |
| 20) | ក្លឹបមិត្តអ្នកអានសៀវភៅ | រាជធានីភ្នំពេញ |
| 21) | សហគមន៍ភូមិប្រលាន | ខេត្តកោះកុង |
| 22) | សហគមន៍តានួន | ខេត្តកោះកុង |